MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប នឹងពិនិត្យរបាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា

ទីក្រុងហ្សឺណែវ (១០ មីនា ២០១៥) - របាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា នឹងត្រូវបានពិនិត្យដោយគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប នៅថ្ងៃអង្គារ ទី១៧ ខែមីនា និងថ្ងៃពុធ ទី១៨ ខែមីនា នៅក្នុងកិច្ចប្រជុំដែលនឹងត្រូវផ្សាយបន្តផ្ទាល់ជាខ្សែវីដេអូបញ្ជូនតាមបណ្តាញអ៊ីនធឺណិត។

ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) កម្ពុជាត្រូវបានតម្រូវឲ្យបញ្ជូនរបាយការណ៍ជាក់ឲ្យមានការពិនិត្យជាទៀងទាត់ ដោយគណៈកម្មាធិការមួយ ដែលមានសមាសភាពអ្នកជំនាញការឯករាជ្យអន្តរជាតិចំនួន១៨ រូប អំពីរបៀបដែលកម្ពុជា បាននិងកំពុងអនុវត្តកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។

កម្ពុជា ដែលជារដ្ឋភាគីមួយក្នុងចំណោមរដ្ឋភាគីទាំងអស់ ១៦៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) បានបញ្ជូនរបាយការណ៍របស់ខ្លួន ស្តីពីការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សទៅគណៈកម្មាធិការនេះ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានបញ្ជូនរបាយការណ៍របស់ខ្លួនផងដែរ ទៅគណៈកម្មាធិការនេះ ដើម្បីធ្វើការពិនិត្យពិចារណា។

កិច្ចសន្ទនារបស់គណៈកម្មាធិការនេះ ជាមួយគណៈប្រតិភូនៃរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាទាំងឡាយទាក់ទងនឹងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនៅកម្ពុជា គ្រោងធ្វើចាប់ពីម៉ោង ១៥:00 - ១៨:00 (ត្រូវនឹងម៉ោង ២១:00 - ២៤:00 នៅរាជធានីភ្នំពេញ) ថ្ងៃទី១៧ ខែមីនា និងម៉ោង ១០:00 - ១៣:00 (ត្រូវនឹងម៉ោង ១៦:00 - ១៩:00) ថ្ងៃទី១៨ ខែមីនា។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅវិមានវីលសុន (Palais Wilson) នៅទីក្រុងហ្សឺណែវ ហើយនឹងត្រូវផ្សាយបន្តផ្ទាល់ជាខ្សែវីដេអូបញ្ជូនតាមបណ្តាញអ៊ីនធឺណិត សូមចូលទៅកាន់គេហទំព័រ៖ http://www.treatybodywebcast.org/។

សន្និសិទសារព័ត៌មានមួយ គ្រោងនឹងធ្វើនៅថ្ងៃព្រហស្បតិ៍ ទី២ ខែមេសា នៅវេលាម៉ោង ១៣:៣០ ក្នុងបន្ទប់ព័ត៌មានលេខ១ វិមានអង្គការសហប្រជាជាតិ (Palais des Nations) នៅទីក្រុងហ្សឺណែវ ដើម្បីពិភាក្សាអំពីសេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការនេះ អំពីប្រទេសកម្ពុជា និងប្រទេសដទៃផ្សេងទៀត ដែលស្ថិតក្រោមការពិនិត្យរបាយការណ៍ ក្នុងនោះមាន ប្រទេសរុស្ស៊ី (Russia) ប្រទេសកូឌីវ័រ (Ivory Coast) ប្រទេសសាយព្រើស (Cyprus) ប្រទេសក្រូអាស៊ី (Croatia) និងប្រទេសម៉ូណាកូ (Monaco) ។

របាយការណ៍របស់ប្រទេស និងបញ្ជីសំនួរទាំងមូល អាចរកឃើញនៅទីនេះ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/SessionDetails1.aspx?SessionID=897&Lang=en។ សេចក្ដីសន្និដ្ឋានចុងក្រោយ នឹងត្រូវបានចេញផ្សាយនៅទីនេះ នៅថ្ងៃព្រហស្បតិ៍ទី២ ខែមេសា។

**ចប់**

សម្រាប់សំណើព័ត៌មានផ្សេងៗ សូមទាក់ទងមក៖ លីហ្ស ស្រូស្សែល្ល (Liz Throssell) អង្គភាពព័ត៌មាននៃការិយាល័យសិទ្ធិមនុស្ស អ.ស.ប តាមរយៈទូរស័ព្ទលេខ (+៤១ (0) ២២ ៩១៧ ៩៤៦៦ ឬតាមរយៈអ៊ីម៉េល ethrossell@ohchr.org)

ដើម្បីស្វែងយល់ច្រើនថែមទៀត អំពីគណៈកម្មាធិការសិទ្ធិមនុស្ស សូមចូលទៅកាន់គេហទំព័រ៖ http://www.ohchr.org/EN/HRBodies/CCPR/Pages/CCPRIndex.aspx

ដើម្បីស្វែងយល់ច្រើនថែមទៀតអំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សូមចូលទៅកាន់គេហទំព័រ៖
http://www.ohchr.org/EN/ProfessionalInterest/Pages/CCPR.aspx

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់អំពីយើងលើបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

**ទ្វីតធើ៖** http://twitter.com/UNrightswire

**ហ្គោហ្គល៖ Google+** gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR